**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៦៨ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការផ្តល់ឋានៈសាស្ត្រាចារ្យគ្រូវិស័យសន្តិសុខជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការប្រែក្លាយ សាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.–**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀន/គ្រូនគរបាលជាតិ ដើម្បីរួមចំណែកអភិវឌ្ឍការបណ្តុះបណ្តាលធនធានមនុស្ស នៅតាមគ្រឹះស្ថានឧត្តមសិក្សាវិស័យសន្តិសុខជាតិ ចំណុះក្រសួងមហាផ្ទៃឱ្យមានគុណភាពខ្ពស់។

**មាត្រា២.–**

អនុក្រឹត្យនេះ មានគោលដៅដូចខាងក្រោម៖

- រៀបចំនីតិវិធី និងយន្តការសម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យ និង ផ្ដល់ឋានៈជា សាស្ត្រាចារ្យ
- កំណត់លក្ខខណ្ឌរបស់បេក្ខជនដែលអាចប្រឡងជ្រើសរើសជា សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ។

**មាត្រា៣.–**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រូបង្រៀន/គ្រូនគរបាលជាតិ នៅតាមគ្រឹះស្ថានឧត្ដមសិក្សាវិស័យសន្តិសុខជាតិ ចំណុះក្រសួងមហាផ្ទៃដែលមានបំណងទទួលឋានៈជា សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ ក្នុងវិស័យសន្តិសុខជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ក្រុមប្រឹក្សាជាតិផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ

**មាត្រា៤.–**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ សរសេរជាអក្សរកាត់ថា **ក.ជ.ស.ស.ជ.** ដែលមានសមាសភាពមកពី៖

| | | |
|---|---|---|
| - តំណាងក្រសួងមហាផ្ទៃ | ១រូប | ប្រធាន |
| - តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| - សាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ | ៦រូប | សមាជិក |

សមាសភាព **ក.ជ.ស.ស.ជ.** មានអាណត្តិ ៣(បី)ឆ្នាំ ហើយអាចបន្តអាណត្តិរបស់ខ្លួនសាជាថ្មីទៀត។ សមាសភាពសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិជាសមាជិក **ក.ជ.ស.ស.ជ.** ត្រូវជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សមាសភាពជាក់ស្ដែងនៃ **ក.ជ.ស.ស.ជ.** ត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា៥. –**

**ក.ជ.ស.ស.ជ.** មានតួនាទី និងភារកិច្ចដូចតទៅ៖

- អនុម័ត និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់ **ក.ជ.ស.ស.ជ.**
- កំណត់បែបបទស្ដីពីការប្រឡងជ្រើសរើសសាស្ត្រាចារ្យ
- អនុម័តយល់ព្រមលើសមាសភាពគណៈមេប្រយោគសម្រាប់វាយតម្លៃសាស្ត្រាចារ្យ
- អនុម័តយល់ព្រមលើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ
- រៀបចំនិងអនុម័តគម្រោងថវិកាសម្រាប់ដំណើរការប្រឡងជ្រើសរើសសាស្ត្រាចារ្យ
- ទទួល និងដោះស្រាយបណ្ដឹងតវ៉ារបស់គណៈមេប្រយោគ ឬបេក្ខជន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល

**មាត្រា៦.–**

សមាជិក **ក.ជ.ស.ស.ជ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា៧.-**

**គ.ជ.ស.ស.ជ.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដង ក្នុង១(មួយ)ឆ្នាំ។

ការប្រព្រឹត្តទៅនៃអង្គប្រជុំ និងរបៀបរបបការងាររបស់ **គ.ជ.ស.ស.ជ.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ស.ស.ជ.**។

**មាត្រា៨.-**

**គ.ជ.ស.ស.ជ.**មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ទីប្រឹក្សា ឬព្រឹទ្ធាចារ្យ ដែលមានបទពិសោធក្នុងការបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ ដើម្បីចូលរួមប្រជុំតាមការចាំបាច់

**គ.ជ.ស.ស.ជ.** អាចទទួលទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិមួយ ចំនួនតាមការចាំបាច់។

**មាត្រា៩.-**

**គ.ជ.ស.ស.ជ.** មាននាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ជាលេខាធិការដ្ឋាន។

លេខាធិការដ្ឋាន **គ.ជ.ស.ស.ជ.**មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ។

**មាត្រា១០.-**

**គ.ជ.ស.ស.ជ.** មានប្រភពធនធានមកពីថវិកាជាតិ ដែលជាកញ្ចប់ថវិការបស់ក្រសួងមហាផ្ទៃ និងថវិកាបានមកពីការដាក់ពាក្យប្រឡងរបស់បេក្ខជន ឬប្រភពផ្សេងៗទៀត។

**មាត្រា១១.-**

**គ.ជ.ស.ស.ជ.** មានសិទ្ធិប្រើត្រាដោយឡែក ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៣
## ឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ
## និងលក្ខខណ្ឌអប្បបរមាសម្រាប់ការប្រឡងជ្រើសរើស

**មាត្រា១២.-**

ឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ ត្រូវបានកំណត់ដូចខាងក្រោម៖

- សាស្ត្រាចារ្យជំនួយ
- សាស្ត្រាចារ្យរង និង
- សាស្ត្រាចារ្យ

**មាត្រា១៣.-**

បេក្ខជនដែលអាចប្រឡងជ្រើសរើសជាសាស្ត្រាចារ្យទៅតាមកម្រិតនីមួយៗ ដូចមានចែងក្នុងមាត្រា ១២ ខាងលើនេះបាន ត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម៖

ក- សាស្ត្រាចារ្យជំនួយ

- មានសញ្ញាបត្រចាប់ពីកម្រិតក្រោយបរិញ្ញាបត្រ ដែលទទួលស្គាល់ដោយក្រសួងមហាផ្ទៃ និង/ឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រសមមូលដែលមានតម្លៃស្មើ ដែលទទួលស្គាល់ដោយគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា
- មានអត្ថបទស្រាវជ្រាវ ដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬនៅក្នុងទស្សនាវដ្តី វិទ្យាសាស្ត្រអន្តរជាតិ
- បានដឹកនាំធ្វើនិក្ខេបបទ ឬបានធ្វើជាអ្នកជំនួយការដឹកនាំធ្វើនិក្ខេបបទ

- បាននិងកំពុងបង្រៀនមួយមុខវិជ្ជាដោយឯករាជ្យ និងស្រាវជ្រាវនៅគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ
- បានចូលរួមស្រាវជ្រាវ និងបោះពុម្ពផ្សាយសៀវភៅសិក្សាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈ ឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។

ខ- សាស្ត្រាចារ្យរង
- បានបម្រើការងារជាសាស្ត្រាចារ្យជំនួយយ៉ាងតិច ៤ (បួន) ឆ្នាំ
- មានអត្ថបទស្រាវជ្រាវថ្មី ដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានចូលរួមសន្និសិទអន្តរជាតិ ដោយធ្វើបទឧទ្ទេសនាម ឬធ្វើបទបង្ហាញជាផ្ទាំងរូបភាព
- បានចូលរួមស្រាវជ្រាវ និងបោះពុម្ពផ្សាយសៀវភៅសិក្សាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈ ឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។

គ- សាស្ត្រាចារ្យ
- បានបម្រើការងារជាសាស្ត្រាចារ្យរងយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ
- មានសញ្ញាបត្របណ្ឌិត
- មានអត្ថបទស្រាវជ្រាវថ្មី ដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានចូលរួមសន្និសិទអន្តរជាតិ ដោយធ្វើបទឧទ្ទេសនាម ឬធ្វើបទបង្ហាញជាផ្ទាំងរូបភាព
- បានចូលរួមស្រាវជ្រាវ និងបោះពុម្ពផ្សាយសៀវភៅសិក្សាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈ ឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។

**មាត្រា១៤._**

លក្ខខណ្ឌលម្អិតពាក់ព័ន្ធនឹងជំនាញនីមួយៗក្នុងវិស័យសន្តិសុខជាតិ សម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យតាមឋានៈនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ស.ស.ជ.**។

## ជំពូកទី៤
## នីតិវិធីនៃការជ្រើសរើស
### ផ្នែកទី១
### នីតិវិធីនៃការជ្រើសរើសគណៈមេប្រយោគ

**មាត្រា១៥._**

ប្រធានបណ្ឌិត្យសភា ឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ ត្រូវបញ្ជូនបញ្ជីសមាសភាពគណៈមេប្រយោគមួយដែលរៀបចំឡើងដោយគណៈកម្មាធិការបច្ចេកទេសនៃគ្រឹះស្ថាន របស់ខ្លួន យោងតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះទៅ **គ.ជ.ស.ស.ជ.** ដើម្បីសុំការអនុម័តយល់ព្រម។ **គ.ជ.ស.ស.ជ.** ត្រូវផ្តល់ការយល់ព្រម ឬ បដិសេធលើសមាសភាពគណៈមេប្រយោគ ក្នុងរយៈ

ពេល ១៥ (ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុង ករណីបដិសេធ **គ.ជ.ស.ស.ជ.**ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរ អំពីមូលហេតុនៃការបដិសេធ ទៅប្រធានបណ្ឌិត្យសភា ឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ ពាក់ព័ន្ធ ដើម្បីធ្វើការរៀបចំសមាសភាពជាថ្មីឡើងវិញ។ បន្ទាប់ពីទទួលបានការយល់ព្រមលើសមាសភាពគណៈមេប្រយោគ ប្រធានបណ្ឌិត្យសភា ឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ ពាក់ព័ន្ធត្រូវបញ្ជូនបញ្ជីសមាសភាពគណៈមេប្រយោគនេះទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីធ្វើការតែងតាំង។

**មាត្រា១៦._**

គណៈមេប្រយោគដែលទទួលបានការតែងតាំង មានឆន្ទានុសិទ្ធិក្នុងការវាយតម្លៃលើបេក្ខជន ដើម្បីទទួលបានឋានៈជាសាស្ត្រាចារ្យណាមួយ។

**មាត្រា១៧._**

សមាសភាពគណៈមេប្រយោគសម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យត្រូវមានដូចខាងក្រោម:

ក- សាស្ត្រាចារ្យជំនួយ

សាមាសភាពគណៈមេប្រយោគមានចំនួន ៧ (ប្រាំពីរ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យរង និងមានអតីតភាពយូរជាងគេ ជាប្រធាន
- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យជំនួយជាសមាជិក ដែលក្នុងនោះត្រូវមានសាស្ត្រាចារ្យក្នុងឋានៈណាមួយមកពីជំនាញឯកទេសនៃ មុខវិជ្ជាដែលបេក្ខជនទទួលបន្ទុកបង្រៀន។

ខ- សាស្ត្រាចារ្យរង

សាមាសភាពគណៈមេប្រយោគមានចំនួន ៧ (ប្រាំពីរ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានអតីតភាពយូរជាងគេ ជាប្រធាន
- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យរងជាសមាជិក ដែលក្នុងនោះត្រូវមានសាស្ត្រាចារ្យ ឬសាស្ត្រាចារ្យរង មកពីជំនាញឯកទេស នៃមុខវិជ្ជាដែលបេក្ខជនទទួលបន្ទុកបង្រៀន។

គ- សាស្ត្រាចារ្យ

សាមាសភាពគណៈមេប្រយោគមានចំនួន ៥ (ប្រាំ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានអតីតភាពយូរជាងគេ ជាប្រធាន
- សាស្ត្រាចារ្យចំនួន២ (ពីរ)រូបជាសមាជិក
- សាស្ត្រាចារ្យដែលអញ្ជើញមកពីគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ ដទៃទៀតចំនួន ២ (ពីរ)រូប ជាសមាជិក

## ផ្នែកទី២
## នីតិវិធីនៃការប្រឡងជ្រើសរើសសាស្ត្រាចារ្យ និងការផ្តល់ឋានៈ

**មាត្រា១៨._**

ចំនួនសាស្ត្រាចារ្យគ្រប់កម្រិតរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗក្នុងវិស័យសន្តិសុខជាតិ ត្រូវកំណត់ដោយប្រកាសដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៩.-**

បេក្ខជនដែលមានបំណងប្រឡងដើម្បីទទួលឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ ដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យស្នើសុំទៅគ្រឹះស្ថានបណ្តុះបណ្តាល វិស័យសន្តិសុខជាតិ ដោយភ្ជាប់មកជាមួយនូវ៖

- ពាក្យស្នើសុំប្រឡងជ្រើសរើស
- ច្បាប់ចម្លងសញ្ញាបត្រវិជ្ជាជីវៈ
- ផែនកការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់បេក្ខជន
- លិខិតថ្កោលទោស
- ឯកសារផ្សេងៗទៀតតាមការចាំបាច់។

គំរូពាក្យស្នើសុំសម្រាប់ការប្រឡងជ្រើសរើសត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ក.ជ.ស.ស.ជ.**។

**មាត្រា២០.-**

បែបបទនៃការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ក.ជ.ស.ស.ជ.**។

**មាត្រា២១.-**

ប្រធានបណ្ឌិត្យសភា ឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ ត្រូវបញ្ជូនលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគទៅ **ក.ជ.ស.ស.ជ.** ដើម្បីសុំការយល់ព្រម។ រាល់ការជំទាស់ណាមួយរបស់ **ក.ជ.ស.ស.ជ** ត្រូវធ្វើការបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុនៃការជំទាស់។

ក្នុងករណីមានវិការៈខាងទម្រង់ណាមួយក្នុងនីតិវិធី នៃការប្រឡងជ្រើសរើសដែលអាចធ្វើនិយតកម្មបាន **ក.ជ.ស.ស.ជ.** ត្រូវធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ ដោយតម្រូវឱ្យគណៈមេប្រយោគកែតម្រូវឡើងវិញ។

បេក្ខជនដែលមិនយល់ព្រមនឹងលទ្ធផល នៃការវាយតម្លៃរបស់គណៈមេប្រយោគ មានសិទ្ធិប្តឹងតវ៉ាទៅ **ក.ជ.ស.ស.ជ.** ដើម្បីស្នើសុំពិនិត្យឡើងវិញ។ ក្នុងការពិនិត្យលើបណ្តឹងតវ៉ានេះ **ក.ជ.ស.ស.ជ.** ត្រូវគោរពតាមអំណាចឆន្ទានុសិទ្ធិរបស់គណៈមេប្រយោគដែលមានចែងក្នុង មាត្រា១៦នៃអនុក្រឹត្យនេះ។

នីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ារបស់បេក្ខជន ត្រូវកំណត់ដោយសេចក្តីសម្រេច របស់ **ក.ជ.ស.ស.ជ.**។

**មាត្រា២២.-**

បន្ទាប់ពីទទួលបានការយល់ព្រមពី **ក.ជ.ស.ស.ជ.** លើលទ្ធផលនៃការវាយតម្លៃ របស់គណៈមេប្រយោគ និងមិនមានការប្តឹងតវ៉ាណាមួយលើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ ប្រធានបណ្ឌិត្យសភា ឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ ពាក់ព័ន្ធ ត្រូវបញ្ជូនលទ្ធផលប្រឡងរបស់បេក្ខជនជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីរៀបចំស្នើតែងតាំង។

ឋានៈជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

## ជំពូកទី៥
## បន្ទុកការងាររបស់សាស្ត្រាចារ្យ

**មាត្រា២៣.-**

បន្ទុកការងាររបស់សាស្ត្រាចារ្យតាមកម្រិតនីមួយៗ ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា២៤.—**

ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន នៅពេលដែលមិនទាន់មាន សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ រាជរដ្ឋាភិបាលត្រូវរៀបចំស្នើតែងតាំងផ្តល់ឋានៈជា សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យមួយចំនួនតាមការចាំបាច់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៥.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រ២៥
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខៈ...១៦៤....អនក្រ.បក ចុះថ្ងៃទី.៣០.ខែ.មេសា.ឆ្នាំ ២០១៤**
**ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ**

**សន្ទានុក្រម**

១.**វិស័យសន្តិសុខជាតិ:** សំដៅដល់ដែនសមត្ថកិច្ចក្នុងការការពារ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា។

២.**គ្រូបង្រៀន:** សំដៅដល់មន្ត្រីនគរបាល ឬ ស៊ីវិល ដែលមិនមែនជាគ្រូនគរបាលជាតិ ហើយដែលបង្រៀនមុខវិជ្ជានៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ។

៣.**គ្រូនគរបាលជាតិ:** សំដៅដល់មន្ត្រីនគរបាលដែលបង្រៀននៅគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសន្តិសុខជាតិ ហើយដែលបានតែងតាំងដោយអនុក្រឹត្យ ឬ ប្រកាសរបស់ក្រសួងមហាផ្ទៃ ។

៤.**សាស្ត្រាចារ្យ:** សំដៅដល់គ្រូបង្រៀន ឬ គ្រូនគរបាលជាតិ ដែលបានទទួលឋានៈតាមអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ។